អង្គការគាំពារកុមារខ្មែរ
CARING FOR YOUNG KHMER

# របាយការណ៍ប្រចាំឆ្នាំនៃកម្មវិធីតម្បាញ
## (ចាប់ពីខែមករា-ធ្នូ ឆ្នាំ២០១៩)

## ១- សាវតារបស់អង្គការ

ក. ឈ្មោះអង្គការ : អង្គការ គាំពាកុមារខ្មែរ (ស៊ី វ៉ាយ ខេ)

ខ. អាស័យដ្ឋាន : ផ្ទះលេខ១៧០ ផ្លូវលេខ៦៣ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន ភ្នំពេញ

គ. បង្កើតគម្រោង : ខែកក្កដា ឆ្នាំ២០០៣

ឃ.ទីកន្លែងអនុវត្តកម្មវិធី : មជ្ឈមណ្ឌលសិក្សាសហគមន៍ ឃុំត្រពាំងក្រសាំង ស្រុកបាទី តាកែវ និង ឃុំអង្គរបាន ស្រុកកងមាស ខេត្តកំពង់ចាម។

## ២- ទស្សនវិស័យ

អង្គការគាំពារកុមារខ្មែរបានប្រមើលមើលពិភពលោកដ៏ល្អ ដែល មនុស្សរស់នៅ ជាពិសេសគឺ សម្រាប់កុមារតូចៗនិងស្រ្តី អាចរីកចំរើនលូតលាស់ ធំធាត់ និងអភិវឌ្ឍខ្លួនឯងបាន ដោយគ្មានភាពអត់ឃ្លាន គ្មានភាពក្រីក្រនេះហើយជាទីដែល មនុស្សរស់នៅក្នុង ភាពសុខដុមរមនា។

## ៣- បេសកម្ម

បេសកម្មរបស់អង្គការគាំពារកុមារខ្មែរគឺគាំទ្រការលូតលាស់នៃសុខភាពរបស់កុមារដែលជួបការលំបាក ដែលត្រូវបានគេបង្ខំឲ្យរស់នៅក្នុងបរិស្ថានដ៏អាក្រក់ ពីសង្គ្រាម គ្រោះមហន្តរាយ ភាពអត់ឃ្លាន និងភាពក្រីក្រ និងជួយគាំទ្រមាតាបិតានិងសហគមន៍របស់គេឲ្យមានឯករាជ្យភាពម្ចាស់ការលើការរស់នៅក្នុងបរិស្ថានដែលមានក្តីមេត្តា។

## ៤- គុណតម្លៃ

"កុមារ ជាអនាគតរបស់យើង" ភាពរីករាយរបស់កុមារនៅថ្ងៃនេះអាចនាំមកនូវសន្តិភាពនៅថ្ងៃស្អែក។

## ៥- គោលបំណងរបស់កម្មវិធី

- គាំទ្រនិងលើកកំពស់ស្ត្រីតាមភូមិ ជាពិសេសស្ត្រីដែលជួបការលំបាក តាមរយៈការបង្កើនប្រាក់ចំណូល ដើម្បីធ្វើអោយជីវភាពប្រសើរឡើង។

- ចូលរួមផ្សព្វផ្សាយ ថែរក្សា និងបង្កើតឡើងវិញ នូវប្រពៃណីសិល្បៈតម្បាញហូលខ្មែរ។
- ជួយអ្នកភូមិឲ្យទទួលបាននូវជំនាញសមស្របផ្នែកតម្បាញហូលប្រពៃណីខ្មែរនិងការ ជ្រលក់ពណ៌ធម្មជាតិ ។
- ពង្រឹងនូវបណ្តាញសិស្សតម្បាញ ដែលរៀនចប់ឲ្យមានប្រសិទ្ធភាព ដើម្បីបង្កើននូវចំណេះដឹងក្នុងការគ្រប់គ្រងអាជីវកម្មរបស់ពួកគាត់។
- ជួយផ្តល់នូវកាគាំទ្រនិងផ្សព្វផ្សាយផលិតផលរបស់អ្នកតម្បាញតាមរយៈការពង្រីកទីផ្សារ។
- គាំទ្រគណៈកម្មការនៃមណ្ឌលសិក្សាសហគមន៍ ដើម្បីគាត់អាចគ្របគ្រងវគ្គជំនាញ កម្មវិធីអក្ខរកម្ម និងសកម្មភាពបណ្ណាល័យនៅក្នុងសហគមន៍។

## ៦- ក្រុមគោលដៅ

- ស្ត្រីរស់នៅតាមភូមិនានាក្នុងបណ្តាស្រុកមួយចំនួនក្នុងខេត្តតាកែវជាពិសេសស្ត្រីដែលជួបការលំបាក។
- ក្រុមអ្នកសហគមន៍ត្រុំក្នុងភូមិអង្គរបានខេត្តកំពង់ចាម

## ៧- អំពីការងារគ្រប់គ្រង

### ក- បុគ្គលិក

| | |
|---|---|
| - លោកស្រី ចាន់ ស្រី | នាយិកាអង្គការ |
| - លោក ព្រំ ប៊ុនធឿន | អ្នកគ្រប់គ្រងរដ្ឋបាល |
| - កញ្ញា យឹង សុផារី | បុគ្គលិកផ្នែកផ្សព្វផ្សាយ ចាប់ផ្តើមការងារពីថ្ងៃទី១ ខែកក្កដា |
| - លោក យី រុន | អ្នកបើកបររថយន្ត (មិនពេញម៉ោង) |
| - លោកស្រី សោម ចាន់ថន | បុគ្គលិកផ្នែកជ្រលក់ពណ៌ |
| - លោក សុខ អ៊ួក | សន្តិសុខប្រចាំមជ្ឈមណ្ឌលតម្បាញ(មិនពេញម៉ោង) |
| - លោកស្រី សៅ ចន្ថា | បណ្ណារក្សមជ្ឈមណ្ឌលសិក្សាសហគមន៍(មិនពេញម៉ោង) |

### ខ- សមាជិកគណៈកម្មការមជ្ឈមណ្ឌលសិក្សាសហគមន៍

| | |
|---|---|
| - លោក ណុប ង៉ែត | ប្រធានគណៈកម្មការ ទទួលបន្ទុកការគ្រប់គ្រងទូទៅ |
| - លោក ស៊ិន ញឿន | អនុប្រធានទី១ ទទួលបន្ទុកកិច្ចការរដ្ឋបាល និង អប់រំ |
| - លោក អ៊ុង អ៊ន | អនុប្រធានទី២ទទួលបន្ទុកកិច្ចការហិរញ្ញវត្ថុនិងទំនាក់ទំនង |
| - លោក សុខ អ៊ួក | សមាជិក ទទួលបន្ទុកកិច្ចការសន្តិសុខ |
| - លោកស្រី សៅ ចន្ថា | សមាជិក ទទួលបន្ទុកការងារបណ្ណាល័យ |

## ៨- កិច្ចសហប្រតិបត្តិការ

ក- នាយកដ្ឋាន អប់រំក្រៅប្រព័ន្ធ នៃក្រសួងអប់រំ យុវជន និងកីឡា

ខ- មន្ទីរអប់រំ យុវជន និងកីឡា ខេត្តតាកែវ

គ- ការិយាល័យ អប់រំ យុវជន និងកីឡា ស្រុកបាទី

ឃ- គណៈកម្មការមជ្ឈមណ្ឌលសិក្សាសហកមន៍ឃុំត្រពាំងក្រសាំង

ង- សិស្សតម្បាញដែលបានបញ្ចប់វគ្គសិក្សានានាដែលរស់នៅតាមភូមិរបស់គម្រោង

ច- ស្ត្រីរស់នៅតាមភូមិក្នុងសហគមន៍ ដែលជាទីកន្លែងអនុវត្តកម្មវិធីនិងជាកន្លែងដែលសិស្សតម្បាញរស់នៅ

ឆ- ស្ត្រីនៅសហគមន៍អង្គរបាន ឃុំអង្គរបាន ស្រុកកងមាស ខេត្តកំពង់ចាម

ជ- អង្គការផ្សេងទៀត

## ៩- កម្មវិធីបណ្តុះបណ្តាលជំនាញតម្បាញ

នៅក្នុងឆ្នាំ២០១៩ អង្គការគាំពារកុមារខ្មែរបានបន្តជួយគាំទ្រអ្នកត្បាញដើម្បីបង្កើនជំនាញរបស់ពួកគាត់លើជំនាញត្បាញនិងជ្រលក់ពណ៌ធម្មជាតិនិងពណ៌ត្រុំ នៅមជ្ឈមណ្ឌលតម្បាញត្រពាំងក្រសាំង។ បុគ្គលិកអង្គការបានធ្វើការជាមួយអ្នកត្បាញ និងផែកគុណភាពការងាររបស់ពួកគាត់យ៉ាងតឹងរឹង លើការចងគាត ជ្រលក់ពណ៌ ជាដើម។ល។ ដើម្បីកែលម្អគុណភាព ជាពិសេសពិតានដែលជាហូលរូបភាពដ៏ពិបាក។





*Activity of product checking at TK center*

### ១. មជ្ឈមណ្ឌលសិក្សាសហគមន៍ត្រពាំងក្រសាំង

#### ក. វគ្គបណ្តុះបណ្តាលលើការអនុវត្តការងារផ្ទាល់

អង្គការគាំពារកុមារខ្មែរបានបន្តផ្តល់ការងារលើការរចនាម៉ូតថ្មីៗសម្រាប់ក្រម៉ា (សូត្រ និងអំបោះ) ក្រណាត់លាត សំពត់ហូល ពិតាន ជាដើម។ល។ ជាមួយការជ្រលក់ពណ៌ធម្មជាតិនិងពណ៌ត្រុំ តាមរយៈវគ្គបណ្តុះបណ្តាលលើការអនុវត្តការងារផ្ទាល់។ ពួកគាត់ជួបការលំបាកយ៉ាងខ្លាំងក្នុងការជ្រលក់ពណ៌ត្រុំ និងត្បាញសំពត់ហូល។ នៅក្នុងឆ្នាំនេះ អ្នកត្បាញចំនួន៦នាក់បានចូលរួមវគ្គនេះ ហើយផលិតគោមផ្សេងៗគ្នារបស់ក្រម៉ាអំបោះ ក្រម៉ាអំបោះកប្បាស ក្រម៉ាសូត្រ ក្រណាត់អំបោះ ក្រណាត់សូត្រ សំពត់ហូល និងពិតានហូល។



សកម្មភាពតផ្ទៃដែលដាច់



សកម្មភាពត្បាញពិតាន



សកម្មភាពចងគាត



សកម្មភាពត្បាញគីម៉ូណុ



សកម្មភាពជ្រលក់ពណ៌



សកម្មភាពត្បាញសំពត់ហូល

### ផលិតផលសម្រេចរបស់សិស្សដែលត្បាញតាមភូមិ (ខែមករា ដល់ខែធ្នូ ឆ្នាំ២០១៩)

| ល.រ | ផលិតផល | ត្រីមាសទី១ | ត្រីមាសទី២ | ត្រីមាសទី៣ | ត្រីមាសទី៤ | សរុប |
|---|---|---|---|---|---|---|
| ១ | ក្រម៉ាអំបោះ (S) | ២៩ក្រម៉ា | | | | **២៩ក្រម៉ា** |
| ២ | ក្រម៉ាអំបោះ (M) | | | ៣០ក្រម៉ា | ៥៩ក្រម៉ា | **៨៩ក្រម៉ា** |
| ៣ | ក្រម៉ាអំបោះ (LE) | ៤១ក្រម៉ា | | | | **៤១ក្រម៉ា** |
| ៤ | ក្រម៉ាសូត្រស (S) | | | ១០ក្រម៉ា | | **១០ក្រម៉ា** |
| ៥ | ក្រម៉ាសូត្រ (M) | ៤៥ក្រម៉ា | | | | **៤៥ក្រម៉ា** |
| ៦ | ក្រម៉ាអំបោះកប្បាស (M) | | | ២៧ក្រម៉ា | | **២៧ក្រម៉ា** |
| ៧ | ក្រម៉ាអំបោះកប្បាស (L) | | | | ១៧ក្រម៉ា | **១៧ក្រម៉ា** |
| ៨ | ក្រម៉ាអំបោះកប្បាស (LE) | | ៤៣ក្រម៉ា | | | **៤៣ក្រម៉ា** |
| ៩ | ក្រណាត់អំបោះ | ១៦.៥ម៉ែត្រ | ៥១ម៉ែត្រ | | ៤១ម៉ែត្រ | **១០៨.៥ម៉ែត្រ** |
| ១០ | សំពត់ហូល | ១ក្បិន | ៣ក្បិន | ១ក្បិន | ២ក្បិនកន្លះ | **៧ក្បិនកន្លះ** |
| ១១ | ក្រណាត់សូត្រ | ២៨.៣ម៉ែត្រ | ១៧ម៉ែត្រ | | | **៤៥.៣ម៉ែត្រ** |
| ១២ | ពិតានហូល ផ្កាច័ន្ទ | ១ផ្ទាំង | ២ផ្ទាំង | ១ផ្ទាំង | | **៤ផ្ទាំង** |
| ១៣ | គីម៉ូណូ | | | | ៣ផ្ទាំង | **៣ផ្ទាំង** |

### ខ. ការសាកល្បងចងម៉ូដនិងជ្រលក់ពណ៌ធម្មជាតិលើក្រម៉ាពណ៌ស

នៅថ្ងៃទី១២ ខែកុម្ភៈ និងថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៩ ក្រុមទស្សនកិច្ចមួយក្រុមមកពីវិទ្យាល័យកាហ្គូស៊ីម៉ា ប្រទេសជប៉ុន បានមកទស្សនាមជ្ឈមណ្ឌលតម្បាញត្រពាំងក្រសាំង និងភូមិដើម្បីសិក្សាពីអីជីវភាពប្រជាជនកម្ពុជា។ នៅពេលនោះ ពួកគាត់បានសាកល្បងយ៉ាងរីករាយជ្រលក់ធម្មជាតិលើក្រម៉ាពណ៌ស ហើយសប្បាយចិត្តយ៉ាងខ្លាំងដោយបានទទួលក្រម៉ាជ្រលក់ពណ៌ជាមួយម៉ូដដែលគាត់បានចងដោយខ្លួនឯងនោះទុកជាអនុស្សាវរីយ៍។





## ២. សហាគមន៍ត្រាំអង្គរបាន (A BIC)

### ក. ការធ្វើល្បាប់មរ

ល្បាប់មរត្រូវបានចាប់ផ្តើមធ្វើនៅខែមិថុនា ឆ្នាំ២០១៩។ ក្នុងឆ្នាំនេះ ដោយសារមានភ្លៀងធ្លាក់តិចចាប់ពីខែមេសា ដល់ខែមិថុនា ពណ៌ល្បាប់មរមិនល្អគ្រប់គ្រាន់។ ដូច្នេះ សមាជិកទាំងអស់សម្រេចចិត្តបញ្ឈប់ការធ្វើនៅខែមិថុនា ហើយចាប់ផ្តើមធ្វើឡើងវិញម្តងទៀតចាប់ពីខែកក្កដា។ តាមការសង្កេតយើងឃើញថា ក្រោយពីមានភ្លៀងធ្លាក់គ្រប់គ្រាន់នៅចុងខែមិថុនា ដើមត្រាំដុះបានល្អ ហើយល្បាប់មរដែលធ្វើបានក្នុងខែកក្កដាមានពណ៌ខៀវស្រស់ស្អាត។

ក្នុងឆ្នាំនេះចំនួនសមាជិកមានការកើនឡើងពី៧នាក់ទៅ៩នាក់។ ហើយពួគេបានសម្រេចចិត្តធ្វើល្បាប់មរផ្សេងគ្នាដោយខ្លួនឯង ប៉ុន្តែពួកគេបានពិភាក្សាគ្នានិងបញ្ជាក់គ្នាទៅវិញទៅមកលើបច្ចេកទេសនិងព្យាយាមត្រួតពិនិត្យពណ៌មរជាមួយគ្នា។ និងព្យាយាមស្វែងរកមូលហេតុនៃបញ្ហាជាមួយគ្នា និងពិភាក្សាគ្នាដើម្បីដោះស្រាយ។ នៅពេលដែលល្បាប់មរមួយចំនួនដែលធ្វើរួចមិនបានខៀវល្អ ពួកគេបានស្នើឲ្យផ្អាកមួយរយៈ។ ហើយផ្លាស់ប្តូរយោបល់គ្នាដើម្បីរក្សាគុណភាពល្អរបស់មរ។

### ការផលិតល្បាប់មរ

| ល | សមាជិក | ទំហំដី | ចំនួនល្បាប់មរធ្វើបាន |
|---|---|---|---|
| ១ | លោកស្រី ឈឺន ថុន | ៥,០០០m$^2$ | ៣២០គីឡូក្រាម |
| ២ | លោកស្រី ភី សុរី | ៨,០០០m$^2$ | ៥០០គីឡូក្រាម |
| ៣ | លោកស្រី ធុច សោភ័ណ្ឌ | ៣,០០០m$^2$ | ៦០០គីឡូក្រាម |
| ៤ | លោកស្រី ចេង គីមឆេង | ៣,៥០០m$^2$ | ២៨០គីឡូក្រាម |
| ៥ | លោកស្រី ថៃម នាង | ៤,០០០m$^2$ | ៣០០គីឡូក្រាម |
| ៦ | លោកស្រី ឆែម វណ្ណារ៉ា | ៤,០០០m$^2$ | ៤០០គីឡូក្រាម |
| ៧ | លោក ចេង ម៉េងថៃ | ៨,៨០០m$^2$ | ៦០០គីឡូក្រាម |
| ៨ | លោកស្រី ឆែម ឈឺន | ២,០០០m$^2$ | ១០០គីឡូក្រាម |
| ៩ | លោកស្រី ចុន មុំ | ៦០០m$^2$ | ៨០គីឡូក្រាម |
| **សរុប** | | **៣៨,៩០០m$^2$** | **៣,១៨០គីឡូក្រាម** |





### ខ. វគ្គបណ្តុះបណ្តាលអំពីការច្នៃម៉ូដក្រម៉ាថ្មី

ចាប់ពីថ្ងៃទី៤ រហូតដល់ថ្ងៃទី៧ ខែមិនា ឆ្នាំអ្នកស្ម័គ្រចិត្តជនជាតិបារាំង កញ្ញា លូអេឡា ហាកែត បានមកភូមិអង្គរបានជាលើកទី២ ដើម្បីបណ្តុះបណ្តាលសមាជិកសហគមន៍ត្រុំអង្គរបាន និង សមាជិកមកពីអង្គការKnK អំពីម៉ូដក្រម៉ាថ្មី សម្រាប់ទាក់ទាញភ្ញៀវទេសចរ។ សមាជិកទាំងអស់ បាន អនុវត្តការច្នៃម៉ូដថ្មីនេះសម្រាប់ផ្ទៃនៅលើក្រដាស។ សមាជិកទាំងអស់សប្បាយរីករាយនឹងបាន អនុវត្ត យ៉ាងល្អលើក្រដាស ដោយគាត់សង្ឃឹមថាភ្ញៀវនឹងសប្បាយរីករាយជាងនេះ ក្នុងការជ្រើសរើសម៉ូដក្រម៉ា ដែលពួកគាត់ធ្វើ។ ពួកគាត់បាននិយាយថាពួកគាត់នឹងធ្វើម៉ូដក្រម៉ានេះនៅពេលបន្ទាប់។





### គ. ការចុះតាមដាននិងការណែនាំអំពីរបៀបប្រើប្រាសទម្រង់

យោងតាមអនុសាស្រ្តរបស់លោកស្រី អ៊ីតុ ណាអូកុ ស្តីអំពីនិរន្តរភាពការងាររបស់ សហគមន៍ត្រុំអង្គរបាន សមាជិកទាំងអស់បានធ្វើតាមនិងចាប់ផ្តើមសកម្មភាពមួយចំនួន។ ក្នុងឆ្នាំ២០១៩ ដើម្បីបញ្ជាក់អំពីសកម្មភាពរបស់គាត់ បុគ្គលិកអង្គការបានចុះតាមដាននិងវាយតម្លៃនៅសហគមន៍ ចំនួន ៦លើក តាមកាលបរិច្ឆេទដូចខាងក្រោម៖

- នៅថ្ងៃទី៦ ខែកុម្ភៈ អ្នកជំនួយការគម្រោងតម្បាញរបស់អង្គការCYK បានឆែកសកម្មភាព ដែលសមាជិកបានគ្រោងនិងលទ្ធផលម្តងមួយៗ ក្នុងអំឡុងពេលនោះ គាត់ក៏បានណែនា

អំពីរបៀបប្រើប្រាសទម្រង់ខ្លះ ដូចជាទម្រង់កត់ត្រាចំនួនភ្ញៀវប្រចាំថ្ងៃ ទម្រោងកត់ត្រាការលក់ប្រចាំថ្ងៃនិងប្រចាំខែ និងទម្រង់ប្រគល់ទទួលផលិតផលជាដើម។ល។ ទម្រង់ទាំងនោះអាចជួយពួកគាត់កត់ត្រានិងត្រួតពិនិត្យផលិតផលនិងចំណូលរបស់ខ្លួនបានត្រឹមត្រូវ ក៏ដូចជាជួយបញ្ចៀសនូវកំហុសលើការទទួលផលិតផលនិងប្រគល់ផលិតផលក្នុងចំណោមសមាជិក។

 

- ចាប់ពីថ្ងៃទី២៨ រហូតដល់ថ្ងៃទី៣១ ខែមិនា បុគ្គលិកអង្គការមកពីមជ្ឈមណ្ឌលតម្បាញត្រពាំងក្រសាំងបានចុះតាមដាននិងវាយតម្លៃលើសកម្មភាពចងម៉ូតជ្រលក់ពណ៌ក្រម៉ាសនិងត្បាញក្រម៉ារបស់សមាជិកសហគមន៍ត្រុំអង្គរបាននៅភូមិអង្គរបានខេត្តកំពង់ចាម។ ក្នុងអំឡុង ពេលនោះ គ្រូបានជួយសមាជិកទាំងអស់ក្នុងការកែលម្អចំណុចដែលខ្វះខាត ដូចជាការគិតទំហំក្រម៉ា ការតភ្ជាប់ផ្ទៃដែលដាច់ ការចងម៉ូដលើក្រម៉ាសនិងការជ្រលក់ជាដើម។ល។
- នៅថ្ងៃទី២៩ តំណាងអង្គការគាំពារកុមារខ្មែរ ក៏បានទៅធ្វើការឆ្លុះបញ្ចាំងអំពីគម្រោងដែលបានគ្រោងនៅក្នុងវគ្គបណ្តុះបណ្តាលលើកមុន លើកឡើងអំពីចំណុចល្អ និងចំណុចដែលបានកែលម្អ និងទទួលស្គាល់នូវអ្វីដែលពួកគាត់បានធ្វើក្នុងរយៈពេលពាក់កណ្តាលឆ្នាំចុងក្រោយ ដើម្បីភាពរីកចំរើនជាមួយគ្នា។

 

- នៅថ្ងៃទី២ខែកក្កដា ថ្ងៃទី១ខែសីហា និងថ្ងៃទី១៩ខែកញ្ញា បុគ្គលិកអង្គការគាំពារកុមារខ្មែរបានចុះពិនិត្យសកម្មភាពគម្រោងរបស់សមាជិកម្នាក់ៗ និងលទ្ធផលរបស់គាត់។

ពិនិត្យមើលការធ្វើល្បាប់មរ គម្រោងផលិត ស្ថានភាពលក់ និងកិច្ចសហការរវាងសមាជិក និងជួបប្រជុំជាមួយសមាជិកដើម្បីពិភាក្សាអំពីគម្រោងបន្តសម្រាប់និរន្តភាពនៃកម្មវិធីរបស់គាត់។

នៅពេលនោះ អង្គការគាំពារកុមារខ្មែរបានគាំទ្រការលក់របស់ពួកគាត់ដោយឧបត្ថម្ភថវិកាសម្រាប់ធ្វើរទេះរុញ ផ្លាកពន្យល់អំពីសកម្មភាពរបស់សហគមន៍ និងផ្លាកឈ្មោះទីតាំងលក់ក្រម៉ារបស់គាត់ក្នុងសហគមន៍។






## ១០- ការតាំងពិព័ណ៌ និងការផ្សព្វផ្សាយ

ដើម្បីផ្សព្វផ្សាយផលិតផលតម្បាញប្រពៃណីខ្មែរដែលជ្រលក់ពណ៌ធម្មជាតិ និងពណ៌ត្រាំ ជាពិសេសសំពត់ហូល និងពិតាន ក៏ដូចជាសម្រាប់ទាក់ទាញភ្ញៀវជាតិនិងអន្តរជាតិ នៅក្នុងឆ្នាំ២០១៩ អង្គការគាំពារកុមារខ្មែរបានចូលរួមកម្មវិធីតាំងពិព័រណ៌ និងកម្មវិធីផ្សេងៗក្នុងស្រុកនិងបរទេសដូចខាងក្រោម៖

- ពិធីផ្សព្វផ្សាយផលិតផលនិងម្ហូបអាហារខ្មែរដែលរៀបចំដោយVillageworks នៅថ្ងៃទី២៣ ខែកុម្ភៈ នៅសារមន្ទីរទួលស្លែង
- កម្មវិធីតាំងពិព័រណ៍បាងកក២០១៩ដែលរៀបចំដោយSACICT ចាប់ពីថ្ងៃទី៤ រហូតដល់ថ្ងៃទី៧ ខែមេសា នៅមជ្ឈមណ្ឌលពិព័រណ៍BITEC ក្រុងបាងកក ប្រទេសថៃ
- មហោស្រពសិល្បៈជាតិដែលរៀបចំដោយក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ចាប់ពីថ្ងៃទី១៤ រហូតដល់ថ្ងៃទី១៦ ខែវិច្ឆិកា នៅបណ្ណាល័យជាតិ
- កម្មវិធីបុណ្យណូអែលដែលរៀបចំដោយក្រុមស្រ្តីអន្តរជាតិនៅថ្ងៃទី២៤ ខែវិច្ឆិកា នៅសាលាអន្តរជាតិកាណាដា
- កម្មវិធីគ្រីស្មាសលើកទី៥ដែលរៀបចំដោយសណ្ឋាគារហ៊ីម៉ាវ៉ារី នៅថ្ងៃទី៧ និងទី៨ ខែធ្នូ នៅសណ្ឋាគារហ៊ីម៉ាវ៉ារី និង

- កម្មវិធីពីព័រណ៍ផលិតផលខ្មែរ និងទំនិញនាំចេញ-នាំចូលលើកទី១៤ ដែលរៀបចំដោយក្រសួងពាណិជ្ជកម្ម ចាប់ពីថ្ងៃទី១៨ រហូតដល់ថ្ងៃទី១៨ ខែធ្នូ នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ។

នៅក្នុងកម្មវិធីតាំងពិពរណ៍និងកម្មវិធីផ្សេងៗ អង្គការគាំពារកុមារខ្មែរបានអនុញ្ញាតិឲ្យសមាជិកសហាគមន៍ត្រុំអង្គរបាន មានឱកាសសិក្សានិងទទួលបទពិសោធន៍ថ្មីក្នុងការទំនាក់ទំនងជាមួយភ្ញៀវ តាំងតុនិងអនុវត្តការលក់ជាដើម។ល។ ដូច្នេះពួកគាត់ពេញចិត្តនឹងការងារដ៏លំបាករបស់ខ្លួននិងអរគុណអង្គការគាំពារកុមារខ្មែរនិងម្ចាស់ជំនួយដែលបានផ្តល់ឱកាសឲ្យពួកគាត់បានចូលរួមកម្មវិធីតាំងពិពរណ៍។ ក្រម៉ាដែលពួកគាត់ផលិតត្រូវបានគេស្គាល់ទូលំទូលាយជាងមុន និងមានប្រជាប្រិយភាពក្នុងចំណោមភ្ញៀវជាតិនិងអន្តរជាតិ។













## ១១- កិច្ចប្រជុំគណៈកម្មការ

កិច្ចប្រជុំប្រចាំខែជាមួយមេឃុំនិងសមាជិកគណៈកម្មការត្រូវបានធ្វើឡើងជារៀងរាល់ខែ ដើម្បីចែករំលែកព័ត៌មានស្តីអំពីសកម្មភាពរបស់មណ្ឌលតម្បាញ ជាពិសេសការបន្តផ្តល់ការងារត្បាញឲ្យសិស្សដែលបានរៀនចប់ ទៅត្បាញនៅមណ្ឌលមណ្ឌលត្រពាំងក្រសាំងនិងនៅតាមផ្ទះរបស់ពួកគេ។

នៅក្នុងខែមិថុនា ឆ្នាំ២០១៩ អង្គការគាំពារកុមារខ្មែរបានផ្តល់ថវិកាសម្រាបស់សាងសង់ដងទង់ជាតិដែលមានតម្លៃ១,២៦៧,៥០០រៀល(ត្រូវនឹង៣១៦ដុល្លាអាមេរិកនិងប៉ែតសិបប្រាំបីសេន) ស្ថិតក្នុងមជ្ឈមណ្ឌលត្រពាំងក្រសាំង តាមការស្នើសុំរបស់សមាជិកគណៈកម្មការតាំងពីឆ្នាំមុន។ ការងារសាងសង់ត្រូវចាប់ ផ្តើមនិងបញ្ចាប់ជាស្ថាពរក្នុងខែកក្កដា ឆ្នាំ២០១៩។

នៅក្នុងខែកញ្ញា ឆ្នាំ២០១៩ សមាជិកគណៈកម្មការបានស្នើឲ្យរៀបចំប្រព័ន្ធលូនៅមុខមណ្ឌលមណ្ឌល ដោយសារផ្លូវត្រូវបានកសាងដោយថវិការដ្ឋ ហើយលូត្រូវបានស្នើឲ្យដាក់ដោយសហាគមន៍ផ្ទាល់

តាមផ្ទះរៀងៗខ្លួន។ ដោយសារគណៈកម្មការមិនមានថវិកា ពួកគាត់បានស្នើឲ្យអង្គការចេញថ្លៃល្វ ហើយពួកគាត់ នឹងចេញថ្លៃដាក់។







## ១១- បណ្ណាល័យសហគមន៍

អង្គការគាំពារកុមារខ្មែរបានធ្វើការជាមួយបណ្ណារក្សពិនិត្យតាមដានកុមារក្នុងបណ្ណាល័យសហគមន៍ និងលើកទឹកចិត្តពួកគាត់ឲ្យមកបណ្ណាល័យដើម្បីទទួលយកចំណេះដឹងបន្ថែមនិងលេងសប្បាយជាមួយមិត្តភ័ក្តិក្នុងសហគមន៍ដើម្បីឲ្យមានទំនាក់ទំនងល្អប្រសើរ។ យើងក៏បានធ្វើការជាមួយសមាជិកគណៈកម្មការក្នុងការទាក់ទាញកុមារឲ្យមកលេងល្បែងសិក្សាផ្សេងៗនិងអានសៀវភៅរឿងផងដែរ។

នៅក្នុងខែកុម្ភៈ អង្គការស៊ីប៉ាបានផ្តល់ទូរដាក់តាំងសៀវភៅនិងសៀវភៅមួយចំនួន សម្រាប់បណ្ណាល័យ ដូច្នេះវាអាចទាក់ទាញកុមារឲ្យមកអានសៀវភៅនៅបណ្ណាល័យ និងខ្ចីសៀវភៅទៅអាននៅផ្ទះច្រើនជាងត្រីមាសមុន។

នៅថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៩ អង្គការស៊ីប៉ាបានចុះមកអប់រំផ្សព្វផ្សាយនៅបណ្ណាល័យត្រពាំងក្រសាំង ក្រោមប្រធានបទ"ការមិនរើសអើងជនពិការគ្រប់ប្រភេទ" ដោយបង្កើតជាល្បែងផ្សេងៗ បែងចែកកុមារជាក្រុមតូចៗចំនួន៥ក្រុម មានកុមារចូលរួមចំនួនសរុប៥៥នាក់។ និងមានចែកទឹកដោះគោជូនកុមារនិងគ្រូផងដែរ។

នៅថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០១៩ អង្គការស៊ីប៉ាបានចុះមកបង្ហាញការពិសោធន៍ដោយប្រើ បច្ចេកវិទ្យាទំនើបលើមុខវិជ្ជាវិទ្យាសាស្ត្រអនុវត្ត និងផ្តល់សៀវភៅថ្មីសម្រាប់បណ្ណាល័យចំនួន២០០ក្បាល។ នៅពេលនោះ ក្រុមការងារក៏បាននិទានរឿងឲ្យកុមារតូចៗស្តាប់។ កុមារសប្បាយរីករាយក្នុង ការផាត់រូប អានសៀវភៅ និងលេងល្បែងផ្គុំអក្សរនិងលេខ។

នៅក្នុងបណ្ណាល័យ បណ្ណារក្សបានអានរឿងនិទានឲ្យកុមារស្តាប់ នាំកុមារអានអក្សរអានលេខ និងរៀបអក្សរ ព្រមទាំងឲ្យកុមារផាត់រូប និងបត់ក្រដាសរូបត្រីនិងផ្កា។ ចំនួនកុមារមកអានសៀវភៅនិងខ្ចីសៀវភៅថយចុះចាប់ពីខែវិច្ឆិកានិងខែធ្នូ ដោយសារពួកគាត់រវល់រៀននៅសាលារដ្ឋនិងសាលាឯកជន។

| លរ | បរិយាយ | ត្រីមាសទី១ | ត្រីមាសទី២ | ត្រីមាសទី៣ | ត្រីមាសទី៤ | **សរុប** |
|---|---|---|---|---|---|---|
| ១ | ចំនួនកុមារ | ២៦៥ | ២៤១ | ៣០១ | ២៤១ | **១,០៤៨** |
| ២ | សៀវភៅខ្ចី | ៤៧៥ | ៣០៣ | ៧០២ | ៥៣៣ | **២,០១៣** |
| ៣ | សៀវភៅថ្មី | ២០០ | ០ | ២០០ | ០ | **៤០០** |
| ៤ | សៀវភៅជួសជុល | ៥ | ២ | ៧ | ៨ | **២២** |
| ៥ | សៀវភៅខូច | ១៩ | ៦ | ១០ | ១០ | **៤៥** |
| ៦ | សៀវភៅកំពុងប្រើ | ១,០៦២ | ១,០៦៨ | ១,២៥៨ | ១,២៤៥ | **១,២៤៥** |





## ១២- សមិទ្ធិផលប្រចាំឆ្នាំ២០១៩

ក-ទោះបីមានការលំបាកក្នុងការជ្រលក់ពណ៌ត្រុំនិងត្បាញសំពត់ហូលក៏ដោយក៏ សិស្សវគ្គបណ្តុះបណ្តាលលើការអនុវត្តលើការងារផ្ទាល់សរុបចំនួន៦នាក់អាចកែលម្អជំនាញរបស់ខ្លួន ដោយផលិតគោមផ្សេងៗគ្នារបស់ក្រម៉ាអំបោះ ក្រម៉ាអំបោះកប្បាស ក្រម៉ាសូត្រ ក្រណាត់អំបោះ ក្រណាត់សូត្រ សំពត់ហូល និងពិតានហូល ហើយអាចរកចំណូលប្រចាំសម្រាប់ទ្រទ្រង់ជីវភាពគ្រួសារ តាមរយៈវគ្គនេះដែរ។

ខ- សមាជិកសហគមន៍ត្រុំអង្គរបានចំនួន៩នាក់ក្លាយជាអ្នកជំនាញ ហើយសហការគ្នាយ៉ាងល្អ និងអាចរក្សាគុណភាពល្បាប់មរបានល្អដោយខ្លួនឯង និងអាចគ្រប់គ្រងថែរក្សាល្បាប់មររបស់ខ្លួនបានយ៉ាងត្រឹមត្រូវ។

គ- សមាជិកសហគមន៍ត្រុំអង្គរបានចំនួន៨នាក់ អាចទទួលអត្ថប្រយោជន៍ពីការងារទាក់ទងនឹងត្រុំ ដូចជាការជ្រលក់អំបោះ ការត្បាញក្រម៉ា និងការចងនិងជ្រលក់ស៊ីប៉ូរិ ជាដើម។ល។ ពួកគាត់អាចច្នៃម៉ូដក្រម៉ាថ្មី ចងម៉ូតនិងជ្រលក់ពណ៌លើក្រម៉ាពណ៌ស ហើយត្បាញក្រម៉ាដែលមានម៉ូដទាក់ទាញជាច្រើន ដើម្បីលក់ឲ្យទេសចរនៅក្នុងភូមិ ដើម្បីរកចំណូលបន្ថែម សម្រាប់ទ្រទ្រង់ជីវភាពគ្រួសារ។ ជាងនេះ

ទៅទៀត សមាជិកមួយចំនួនមានឱកាសចូលរួមលក់ក្នុងកម្មវិធីតាំងពិព័រណ៌មួយចំនួន ដូច្នេះគាត់មានមោទនភាពនិងមានភាពជឿជាក់លើការងាររបស់គាត់បន្ថែមទៀត។

ឃ- សិក្ខាសាលាជ្រលក់ពណ៌ធម្មជាតិលើក្រម៉ាពណ៌ស មានប្រជាប្រិយភាពសម្រាប់ជនបរទេសជាពេសិសក្រុមទស្សនកិច្ចសិក្សា។ មាននិស្សិតជប៉ុនចំនួន២៨នាក់បានចូលរួមវគ្គសិក្ខាសាលានេះយ៉ាងរីករាយ ហើយសប្បាយចិត្តយ៉ាងខ្លាំងដោយទទួលបាននូវក្រម៉ាដែលគាត់ចងគោមនិងជ្រលក់ពណ៌ដោយខ្លួនឯង។

ង- សកម្មភាពបណ្ណាល័យសហគមន៍បានបន្ត២ថ្ងៃក្នុង១សប្តាហ៍ក្នុងមជ្ឈមណ្ឌលសិក្សាសហគមន៍និងកុមារចំនួន៨៧នាក់ជាមធ្យមក្នុង១ខែបានចូលរួមជាប្រចាំក្នុងបណ្ណាល័យ។

ឈ- ការសហការយ៉ាងល្អជាមួយសមាជិកគណៈកម្មការបានផ្តល់ជំនាញ និងចំនេះដឹងដល់ប្រជាពលរដ្ឋក្នុងសហគមន៍តាមរយៈបណ្ណាល័យ និងវគ្គបណ្តុះបណ្តាល។

## ១៣- គម្រោងចំណាយប្រចាំឆ្នាំ ២០១៩ ជាលុយដុល្លាសហរដ្ឋអាមេរិក

| | |
|---|---|
| ១) ចំណាយសម្រាប់គម្រោងពណ៌ត្រុំក្នុងខេត្តកំពង់ចាម | ១១,០៥៩.១៦ |
| ២) ចំណាយសម្រាប់សម្ភារនិងបរិក្ខារបណ្តុះបណ្តាល | ៧,៦៧៥.៨៦ |
| ៣) ចំណាយលើការជួសជុលនៅមណ្ឌលតម្បាញ | ៦០៣.៣៨ |
| ៤) ចំណាយសម្រាប់ផ្គត់ផ្គង់ទីផ្សារសិស្ស | ៧,៨៥៥.៥៣ |
| ៥) ចំណាយលើប្រាក់បៀវត្សបុគ្គលិកគម្រោង | ១៥,៩៧៨.២១ |
| ៦) ចំណាយលើការដឹកជញ្ជូន ប្រេង និងការថែទាំរថយន្ត | ៨,៥៥២.៩២ |
| ៧) ចំណាយលើថ្លៃរដ្ឋបាល | ៥,៣៩២.០០ |
| **សរុប** | **៥៣,០០១.១៦** |

**(ប្រាំម៉ឺនបីពាន់មួយដុល្លានិងដប់ប្រាំមួយសេន)**

## ១៤- ផែនការត្រីមាសបន្ទាប់

នៅក្នុងត្រីមាសបន្ទាប់

- អង្គការគាំពារកុមារខ្មែរនឹងបន្តគាំទ្រសិស្សដែលបានរៀនចប់ និងអ្នកត្បាញតាមរយៈការបណ្តុះបណ្តាលលើការអនុវត្តលើការងារផ្ទាល់ដោយៈ
  - ផ្តល់ឱកាសឲ្យពួកគាត់ផលិតក្រម៉ា ក្រណាត់ សំពត់ហូលគោមថ្មីៗនិងពិតានជ្រលក់ពណ៌ធម្មជាតិនិងពណ៌ត្រុំ។
  - ឲ្យពួកគាត់សាកល្បងជាមួយការច្នៃម៉ូដថ្មីៗដែលពិបាកលើក្រម៉ានិងក្រណាត់ ដោយប្រើទាំងអំបោះនិងសូត្រ។
  - ឲ្យពួកគាត់អនុវត្តការជ្រលក់ពណ៌ត្រុំនៅមណ្ឌលដើម្បីបានពណ៌ខៀវផ្សេងៗ។
  - ឲ្យពួកគាត់ស្រាវជ្រាវនិងពិសោធន៍ពណ៌ជាមួយវត្ថុធាតុដើមធម្មជាតិដើម្បីកែលម្អគុណភាពផលិតផលរបស់គាត់។

- អង្គការCYK នឹងផ្តល់ថវិកាទិញលួសម្រាប់រៀបចំប្រព័ន្ធលួនៅមុខមជ្ឈមណ្ឌលត្រពាំងក្រសាំង
- អង្គការCYK នឹងធ្វើការជាមួយសមាជិកគណៈកម្មការដើម្បីចែករំលែកការងារនិងទាក់ទាញកុមារមកបណ្ណាល័យសហគមន៍បន្ថែម។
- សម្រាប់គម្រោងក្នុងខេត្តកំពង់ចាម នៅក្នុងត្រីមាសបន្ទាប់
  - នៅក្នុងខែមករា ឆ្នាំ២០២០ អង្គការCYK នឹងបន្តចុះតាមដាននិងវាយតម្លៃលើសកម្មភាពរបស់គាត់ ជាពិសេសការជ្រលក់ពណ៌ត្រុំ ការត្បាញ គម្រោងផលិត និងគម្រោងលក់ជាដើម ។ល។

# ១៥- ការវាយតម្លៃ

## ក ចំណុចខ្លាំង

- សិស្សទាំងអស់អាចទទួលជំនាញសមស្របអំពីមូលដ្ឋាននៃការត្បាញពិតានដែលមានគោមស្មុគស្មាញ ជាពិសេសបច្ចេកទេសនៃការចងគោម។
- ការងារជ្រលក់ពណ៌ត្រុំធម្មជាតិបានទាក់ទាញមនុស្សជាច្រើននិងលើកទឹកចិត្តសមាជិកឲ្យចូលរួមវគ្គជំនាញដ៏លំបាកនេះកាន់តែច្រើន។
- ការសម្របសម្រួលល្អអាចបំពេញតម្រូវការអ្នកសិក្សានូវជំនាញតម្បាញជាក់លាក់។
- មណ្ឌលតម្បាញបន្តជួយគាំទ្រអ្នកតម្បាញសហគមន៍ឲ្យទទួលបានចំណូលច្រើនជាងមុន។
- កិច្ចសហប្រតិបត្តិការល្អជាមួយសមាជិកគណៈកម្មការក្នុងការចែករំលែកព័ត៌មាន និងជំនាញតម្បាញដល់អ្នកតម្បាញតាមភូមិ។

## ខ- ចំណុចខ្សោយ

- មានការលំបាកក្នុងការស្វែងរកទីផ្សារផ្គត់ផ្គង់ផលិតផលជ្រលក់ពណ៌ធម្មជាតិក្នុងសហគមន៍របស់គេនិងជំនាញជាន់ខ្ពស់នៃត្បាញក្រណាត់ពិតាន។
- ដោយសារស្ថានភាពសេដ្ឋកិច្ចនិងជីវភាពគ្រួសារ សិស្សដែលរៀនចប់មួយចំនួនបានបោះបង់ការងារត្បាញរបស់ខ្លួន ហើយទៅធ្វើការងារនៅរោងចក្រ។ ដូច្នេះអង្គការគាំពារកុមារខ្មែរជួបការ លំបាកក្នុងការជ្រើសរើសសិស្សដែលមានសមត្ថភាពសម្រាប់វគ្គ។
- ការខ្វះខាតវត្ថុធាតុដើមនិងសម្ភារតម្បាញជាបញ្ហាប្រឈមខ្លាំងក្នុងវិស័យតម្បាញ។ បច្ចុប្បន្នយើងជួបការលំបាកក្នុងការរកសូត្រខ្មែរដែលមានគុណភាពខ្ពស់ និងវត្ថុធាតុដើមសម្រាប់ជ្រលក់ ពណ៌ធម្មជាតិដូចជាល័ក្ខ ព្រហ៊ូត ដែលតែងតែប្រើប្រាសសម្រាប់តម្បាញ។
- មានការយឺតយ៉ាវក្នុងការធ្វើផែនការ និងយុទ្ធសាស្ត្រសម្រាប់និរន្តភាពគម្រោងនាពេលអនាគត។

## ១៦- សេចក្តីសន្និដ្ឋាន

វគ្គបណ្តុះបណ្តាលតាមរយៈការអនុវត្តផ្ទាល់នៅមានប្រជាប្រិយភាពនិងទាក់ទាញសិស្សដែលរៀនចប់មួយចំនួនឲ្យបន្តការងារត្បាញរបស់គេនៅផ្ទះនិងនៅមណ្ឌលតម្បាញត្រពាំងក្រសាំង។ ពួកគាត់បានកែលម្អគុណភាពផលិតផលរបស់ខ្លួនប្រសើរជាងមុនតាមរយៈវគ្គនេះ ហើយអាចរកចំណូលជាប្រចាំសម្រាប់ទ្រទ្រង់ជីវភាពគ្រួសារបាន។

សមាជិកសហគមន៍ត្រាំអង្គរបានបានសហការគ្នាយ៉ាងល្អប្រសើរ ក្នុងការរក្សាគុណភាពនៃល្បាប់មរ និងជ្រលក់ដោយខ្លួនឯង។ ហើយពួកគេអាចចងម៉ូដជ្រលក់ពណ៌ជាច្រើនយ៉ាង និងត្បាញក្រម៉ាម៉ូតទាក់ទាញជាច្រើន សម្រាប់លក់ក្នុងភូមិ ដើម្បីរកចំណូលទ្រទ្រង់ជីវភាពគ្រួសារបន្ថែម។

ដោយមានកិច្ចសហការល្អរបស់សមាជិកគណៈកម្មការ អង្គការគាំពារកុមារខ្មែរអាចបើកវគ្គបណ្តុះបណ្តាលនិងផ្តល់ការងារតម្បាញក្នុងសហគមន៍បានយ៉ាងរលូន។ កិច្ចប្រជុំគណៈកម្មការប្រចាំខែអាចជួយឲ្យយើងចែករំលែកព័ត៌មានស្តីពីស្ថានភាពនិងដំណើរការសកម្មភាពរបស់វគ្គឬគម្រោង។ ហើយបណ្ណាល័យសហគមន៍បានជួយកុមារឲ្យទទួលបាននូវចំណេះដឹងបន្ថែម តាមរយៈការលេងល្បែងសិក្សា និងការអានសៀវភៅរឿង។

រាជធានីភ្នំពេញ ថ្ងៃសុក្រ ១រោច ខែបុស្ស ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
ត្រូវនឹងថ្ងៃទី១០ ខែមករា ឆ្នាំ២០២០
**នាយិកាអន្តការ**

**ចាន់ ស្រី**

Phnom Penh: #170, St. Preah Trasak Paem (63), Sangkat Boeung Keng Kang I, Khan Chamkar Mon, Phnom Penh, Cambodia
P.O Box: 12 Phnom Penh, Cambodia, Tel/Fax: (855) 23-210 849, Email: info@cyk.org.kh URL: www.cyk.org.kh

Head Office: Aoki Building 2A, Taito 1-12-11, Taito-ku, Tokyo, Japan 〒 110-0016
Tel: 03-6803-2015, Fax: 03.6803-2016, E-mail: info@cyr.or.jp